**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**លេខៈ** ៤៧ **អយក.** សាសរ

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតគណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំ នៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណោះទូទៅ

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៥៨ អនក្រ.បក ចុះថ្ងៃទី១១ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- តាមការចាំបាច់របស់ក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**ប្រការ១ .-**

ត្រូវបង្កើតគណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណោះទូទៅ ដើម្បីអនុវត្តកម្មវិធីលើកកម្ពស់គុណភាពអប់រំនិងឥរិយាបថសិស្សនៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណោះទូទៅ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទៈ (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារៈ (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែលៈ info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ .-**

សមាសភាពនៃគណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សា និងអប់រំចំណេះទូទៅ មានដូចខាងក្រោម៖

| | | |
|---|---|---|
| -រដ្ឋមន្ត្រី | | ប្រធាន |
| -រដ្ឋលេខាធិការ | ០២រូប | អនុប្រធាន |
| -អនុរដ្ឋលេខាធិការ | ០១រូប | សមាជិក |
| -អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | | សមាជិក |
| -អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ | | សមាជិក |
| -អគ្គាធិការនៃអគ្គាធិការដ្ឋាន | | សមាជិក |
| -អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ | | សមាជិក |
| -នាយកវិទ្យាស្ថានជាតិអប់រំ | | សមាជិក |
| -សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ | | សមាជិក |
| -អគ្គាធិការរងនៃអគ្គាធិការដ្ឋាន | ០១រូប | សមាជិក |
| -ប្រធាននាយកដ្ឋានព័ត៌មាននិងកិច្ចការអាស៊ាន | | សមាជិក |
| -ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹតការ | | សមាជិក |
| -ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ | | សមាជិក |
| -ប្រធាននាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា | | សមាជិក |
| -ប្រធាននាយកដ្ឋានបុគ្គលិក | | សមាជិក |
| -ប្រធាននាយកដ្ឋាននីតិកម្ម | | សមាជិក |
| -អធិការនៃអធិការដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ | | សមាជិក |
| -ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង | | សមាជិក |
| -ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ | | សមាជិកអចិន្ត្រៃយ៍ |
| -តំណាងដៃគូអភិវឌ្ឍន៍វិស័យអប់រំ | | សមាជិក |

**ប្រការ៣ .-**

គណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ មានភារកិច្ចដូចខាងក្រោម៖

- ពិនិត្យនិងសម្រេចលើលទ្ធផលនៃការវាយតម្លៃអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា
- ពិនិត្យនិងសម្រេចលើគោលនយោបាយអប់រំដោយផ្អែកលើលទ្ធផលវាយតម្លៃ
- កោះប្រជុំទៅតាមកាលកំណត់ជាមួយគណៈកម្មការបច្ចេកទេស ដើម្បីពិនិត្យការរីកចម្រើនក្នុងការអនុវត្ត និងផ្តល់ការណែនាំលើលទ្ធផលបឋមដែលបានរកឃើញ

- ពិនិត្យ ផ្តល់អនុសាសន៍ និងសម្រេចលើគោលការណ៍ទាំងឡាយដែលរៀបចំដោយគណៈកម្មការបច្ចេកទេសនិងលេខាធិការដ្ឋាន
- អនុម័តលើឯកសារ ឧបករណ៍ និងផលិតផលទាំងឡាយដែលទាក់ទងនឹងការវាយតម្លៃ
- សហការជាមួយក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ដៃគូអភិវឌ្ឍន៍ ដើម្បីដំណើរការវាយតម្លៃអប់រំឱ្យសម្រេចតាមគោលដៅ
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនក្រសួងអប់រំ យុវជន និងកីឡា។

**ប្រការ៤.-**

គណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ មានលេខាធិការដ្ឋាននៅក្នុងនាយកដ្ឋានធានាគុណភាពអប់រំ។

លេខាធិការដ្ឋានត្រូវដឹកនាំដោយប្រធានមួយរូប អនុប្រធានមួយរូប និងសមាជិកមួយចំនួនតាមការចាំបាច់។

លេខាធិការដ្ឋានគឺជាសេនាធិការឱ្យគណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ។

**ប្រការ៥.-**

គណៈកម្មការគ្រប់គ្រងនិងដឹកនាំប្រព័ន្ធវាយតម្លៃអប់រំនៅកម្រិតមត្តេយ្យសិក្សានិងអប់រំចំណេះទូទៅ ដំណើរការការងាររបស់ខ្លួនក្រោមការដឹកនាំរបស់ប្រធាន និងតាមផែនការដែលបានកំណត់ទុក។

**ប្រការ៦.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះត្រូវទុកជានិរាករណ៍។

**ប្រការ៧.-**

អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានគោលនយោបាយនិងផែនការ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានធានាគុណភាពអប់រំ និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែ តុលា ឆ្នាំ២០១៥

**កន្លែងទទួល ៖**

- អង្គភាពក្រោមឱវាទក្រសួង
- ខុទ្ទកាល័យក្រសួង អ.យ.ក. "ដើម្បីជូនជ្រាប និងសហការ"
- ដូចប្រការ ៧
- ឯកសារ-កាលប្បវត្តិ នា. នីតិកម្ម

បណ្ឌិត ហង់ ជួន ណារ៉ុន